cirad
AGRICULTURAL RESEARCH
FOR DEVELOPMENT

# ដំណាំគម្របដី៖ សម្ព័ន្ធមិត្តរបស់ដី ដំណាំ និងកសិករ

## សៀវភៅណែនាំអនុវត្តក្នុងបរិបទប្រទេសកម្ពុជា

កែសម្រួលដោយ៖ សៀង ស្រីមុំ, ឡេង វីរ៉ា, ស វ៉េង, Evelyne WADROBERT, Mathilde SESTER, Florent TIVET, គង់ វ៉ាដា, ស្រ៊ុន ខេម៉ា, ជូ ចាន់ភក្តី, សេង វ៉ាង

# មាតិកា


## សេចក្តីផ្តើម

## អ្វីទៅជាដំណាំគម្របដី ?

- និយមន័យ
- អត្ថប្រយោជន៍នៃដំណាំគម្របដី
- ហេតុអ្វីយើងត្រូវការដីដែលមានសុខភាពល្អ ?

## គ្រួសារស្មៅ / Poacae

- ម៉ូឡាតូ២ ( Brachiaria mulato II )
- រូស្សី ( Brachiaria ruziziensis )
- ស្មៅជើងក្រាស់ដើមខ្ពស់ ( Eleusine coracana )
- មីលែត ( Pennisetum glaucum )
- ស្កួយ ( Sorghum bicolor )

## គ្រួសារសណ្តែក / Fabacae

- សណ្តែកដីព្រៃ ( *Arachis repens* )
- សណ្តែកអង្រៃ ( Cajanus cajan )
- សង់ត្រូ ( Centrosema pascuorum )
- ចង្រ្កងស្វាស្ទឹកតូច ( Crotalaria juncea )
- ចង្រ្កងស្វាស្លឹកធំ ( Crotalaria ochroleuca )
- ពពាយស្បែក ( Dolichos lablab )
- សណ្តែកសៀងព្រៃ ( Neonotonia wightii )
- គូឌូត្រូពិច ( Pueraria phaseoloides )
- ស្នោរ ( Sesbania sesban )
- ស្ទីឡូ ( Stylosanthes guianensis )
- សណ្តែកកត្តិក ( *Vigna umbellata* )
- សណ្តែកអង្គុយ ( Vigna unguiculata )

## គ្រួសារ Malvaceae

- ក្រចៅ ( *Corchorus capsularis* )
- ក្រចៅបន្លា ( *Hibiscus cannabinus* )

## សេចក្តីថ្លែងអំណរគុណ


©CARDEC, Kampong Cham

# សេចក្ដីផ្ដើម

សៀវភៅណែនាំនេះនឹងបង្កើនការយល់ដឹងឱ្យកាន់តែច្បាស់ពីដំណាំគម្របដីរួមមាន លក្ខណៈរូបសាស្ត្រ អត្ថប្រយោជន៍ និងការពិចារណា ក្នុងការជ្រើសរើសប្រើប្រាស់ទៅតាមប្រព័ន្ធដាំដុះផ្សេងៗគ្នា។

សៀវភៅណែនាំនេះបែងចែកចេញជាបីជំពូក។ ជំពូកទី១ សំដៅទៅលើលក្ខណៈរូបសាស្ត្រសំខាន់ៗនៃដំណាំគម្របដី។ ជំពូកទី២ ពន្យល់ពីរបៀបជ្រើសរើសដំណាំគម្របដែលសមស្របបំផុត។ ជំពូកទី៣ ណែនាំពីជំហានចម្បងៗដើម្បីទទួលបានភាពជោគជ័យក្នុងការផលិតគ្រាប់ពូជដំណាំគម្របដីប្រភេទទាំងនេះ។

ដំណាំគម្របដីដើរតួនាទីយ៉ាងសំខាន់ក្នុងវិស័យកសិកម្ម ដូចជា៖ ជួយការពារដី បង្កើនជីជាតិដីនិងជីវចម្រុះ កាត់បន្ថយការហូរច្រោះ និងផ្ដល់សារធាតុចិញ្ចឹមបន្ថែមសម្រាប់ដំណាំចម្បង។

អ្នកនឹងរៀនពីរបៀបជ្រើសរើសដំណាំគម្របដីដែលសមស្របបំផុតដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចតទៅ គុណភាព និងប្រភេទដី អាកាសធាតុទៅតាមតំបន់របស់អ្នក តម្រូវការសារធាតុចិញ្ចឹមរបស់ដំណាំ ក៏ដូចជាគោលបំណងអាទិភាពផ្ទាល់ខ្លួនរបស់អ្នកក្នុងនាមជាអ្នកជំនាញផ្នែកក្សេត្រសាស្ត្រ ឬជាកសិករ។ អ្នកនឹងរកឃើញពីអត្ថប្រយោជន៍រយៈពេលវែងដែលរុក្ខជាតិទាំងនេះនឹងផ្ដល់ឱ្យក្នុងប្រព័ន្ធផលិតកម្មរបស់អ្នក។

នៅចុងបញ្ចប់នៃសៀវភៅណែនាំនេះ អ្នកនឹងអាចជ្រើស រើសដំណាំគម្របដីដែលសមស្របបំផុតទៅតាមបរិបទនិងតម្រូវការរបស់អ្នកដើម្បីជម្រុញផលិតកម្មកសិកម្មប្រកបដោយនិរន្តរភាព។



©CARDEC, Kampong Cham

# អ្វីទៅជាដំណាំគម្របដី?

ដំណាំគ្របដី គឺជាប្រភេទរុក្ខជាតិអចិន្ត្រៃយ៍ ឬពាក់កណ្តាលអចិន្ត្រៃយ៍ ដែលត្រូវបានដាំដុះជាចម្បងដើម្បីគ្របដីនៅចន្លោះពេល ឬក្នុងអំឡុងពេលនៃវដ្តដំណាំ។ វាដើរតួនាទីយ៉ាងសំខាន់ក្នុងការការពារដី កែលម្អរចនាសម្ព័ន្ធដី បង្កើនបរិមាណសារធាតុសរីរាង្គក្នុងដី និងផ្តល់សេវាកម្មអេកូឡូស៊ីជាច្រើនដូចជា ការទប់ស្កាត់សំណឹកដី ការចាប់យកសារធាតុអាសូត និងការកាត់បន្ថយស្មៅចង្រៃ។

ប្រភេទដំណាំជាច្រើនដែលអាចជ្រើសរើសជាដំណាំគម្របដីបាន គឺអាស្រ័យលើលក្ខខណ្ឌអាកាសធាតុ ប្រភេទដី និងបញ្ហាប្រឈមផ្នែកក្សេត្រសាស្ត្រដែលត្រូវដោះស្រាយដូចជា (ដីហាប់ណែន សម្ពាធស្មៅចង្រៃ ការថយចុះនូវជីជាតិដី..)។ ប្រភេទដំណាំទាំងនេះជាទូទៅត្រូវបានចាត់ថ្នាក់ជាពីរក្រុមធំៗ៖ ដំណាំរយៈពេលខ្លីប្រចាំឆ្នាំដូចជាចង្ក្រងស្វាស្លឹកធំ (*Crotalaria juncea*) និងដំណាំរយៈពេលវែងច្រើនឆ្នាំដូចជាស្ទីឡូ (*Stylosanthes guianensis*)។

ដំណាំគម្របដីអាចដាំដុះបានតាមវិធីសាស្ត្រជាច្រើនអាស្រ័យលើគោលបំណងចម្បងរបស់កសិករ។ កសិករប្រើប្រាស់បច្ចេកទេសដូចជាការដាំដំណាំបណ្តាក់ (Relay cropping) ការសាបព្រោះបន្ថែមលើដំណាំឬកាកសំណល់ដំណាំផ្ទាល់(Overseeding) ឬការដាំក្នុងចន្លោះរង (Interseeding) ទាំងការលាយពូជគម្របដីច្រើនមុខបញ្ចូលគ្នា ឬប្រើពូជតែមួយប្រភេទ។ ការអនុវត្តទាំងនេះមិនត្រឹមតែជួយគ្រប់គ្រងសំណឹកដីប៉ុណ្ណោះទេ តែវាថែមទាំងផ្តល់អត្ថប្រយោជន៍ផ្សេងទៀតដូចជា ការបង្កើនសារធាតុអាសូត បង្កើនជីជាតិដីនិងវដ្តនៃសារធាតុចិញ្ចឹម និងការកែលម្អរចនាសម្ព័ន្ធដី។ អត្ថប្រយោជន៍ទាំងនេះនឹងត្រូវរៀបរាប់លម្អិតនៅក្នុងផ្នែកបន្តបន្ទាប់ដូចខាងក្រោម។


បង្ក្រងស្វាស្លឹកធំ
**Crotalaria ochroleuca**


មីលែត
**Pearl millet**


ក្រចៅបន្លា
**Kenaf**


សណ្តែកកត្តិក
**Rice bean**


ពពាយស្បែក
**Dolichos lablab**


សង់ត្រូ
**Centrosema pascuorum**

# អត្ថប្រយោជន៍ដំណាំគម្របដី

ដំណាំគម្របដី គឺជាធនធានដ៏មានតម្លៃសម្រាប់ដី និងរុក្ខជាតិ។ ដោយសារតែការផលិតជីវម៉ាស់ដ៏ច្រើនរបស់វា (រួមមាន ដើម ស្លឹក និងប្រព័ន្ធឫស) ពួកវាដើរតួនាទីយ៉ាងសំខាន់ក្នុងការទប់ស្កាត់សំណឹកដី ហើយក៏ជួយស្រូបយកទឹក និងសារធាតុចិញ្ចឹមពីស្រទាប់ដីជ្រៅៗតាមរយៈប្រព័ន្ធឫសដ៏ជ្រៅរបស់វា។ ពួកវាក៏ជាប្រភពនៃកាបូនផងដែរ ហើយរួមចំណែកដល់ការការពារដីពីគ្រោះរាំងស្ងួតដោយកាត់បន្ថយរំហួត និងរក្សាសំណើមដី។

តាមរយៈឫស ដើម និងស្លឹករបស់វា ដំណាំគម្របដីបង្កើនការផលិតជីវម៉ាស់ទាំងផ្នែកខាងលើដីនិងក្រោមដីដែលជួយជម្រុញសកម្មភាពជីវសាស្ត្រនៅក្នុងដី។ ដំណាំគម្របដីមួយចំនួនមានទំនាក់ទំនងជាមួយបាក់តេរីនៅតំបន់ ឫស rhizobia ក្នុងការចាប់យកឧស្ម័នអាសូតនីជ្រូសែន($N_2$) និងបំប្លែងទៅជាជីនីត្រាត(អាសូត) ដែលជាសារធាតុចិញ្ចឹមចាំបាច់ដែលដំណាំចម្បងត្រូវការ ដោយសារតែដំណាំចម្បងៗមិនអាចចាប់យកសារធាតុអាសូតពីបរិយាកាសបានទេ។

ដំណាំគម្របដីជាច្រើននៅតែមានពណ៌បៃតងក្នុងរដូវប្រាំង ហើយរក្សាឫសរស់ក្នុងដីអំឡុងពេលដីទំនេរដោយជួយទ្រទ្រង់ និងទាក់ទាញបណ្តាញផ្សិតដូចជាពពួក mycorrhizae ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើនជីជាតិដី។ នៅពេលដែលសារធាតុសរីរាង្គក្នុងដីកាន់តែច្រើន សកម្មភាពជីវសាស្ត្រក៏កាន់តែខ្ពស់ដែលផ្តល់អត្ថប្រយោជន៍ដល់សុខភាពដំណាំចម្បង។ ដំណាំគម្របដីជួយកែលម្អរចនាសម្ព័ន្ធដីដោយបង្កើនរន្ធដី និងជួយឲ្យទឹកជ្រាបចូលក្នុងស្រទាប់ដីបានល្អ។

ដំណាំគម្របដីមួយចំនួនទាក់ទាញនូវសត្វល្អិតមានប្រយោជន៍ ចំណែកឯប្រភេទខ្លះទៀតបណ្តេញសត្វល្អិតចង្រៃ ដែលវាជួយកាត់បន្ថយការបំផ្លាញទៅលើដំណាំចម្បង។ លើសពីនេះទៀតដំណាំគម្របដីជួយកាត់បន្ថយការរីក រាលដាលនៃវត្ថុមានស្មៅចង្រៃតាមរយៈការលូតលាស់ពាសពេញផ្ទៃដី និងបង្កើតជាគម្របដីដ៏ក្រាស់។




រូបភាពទី ១ - ឥទ្ធិពលនៃដំណាំគម្របដីនៅក្នុងប្រព័ន្ធអេកូឡូស៊ី

# ហេតុអ្វីយើងត្រូវការដីដែលមានសុខភាពល្អ?

ដីមានសុខភាពល្អ គឺជាមូលដ្ឋានគ្រឹះនៃជីវិតប្រកបដោយនិរន្តរភាព ដោយជួយគាំទ្រដល់ការផលិតស្បៀងអាហារ ទឹកស្អាត ជីវៈចម្រុះ ជួយដល់ស្ថេរភាពអាកាសធាតុ និងស្ថិរភាពប្រព័ន្ធអេកូឡូស៊ី។



ដំណាំគ្របដី គឺជាឧបករណ៍ដ៏មានប្រសិទ្ធភាពមួយសម្រាប់ការកែលម្អសុខភាពដីតាមវិធីសាស្ត្រជាច្រើនប្រភេទដែលមានទំនាក់ទំនងគ្នាទៅវិញទៅមក។



អត្ថប្រយោជន៍សំខាន់ៗនៃដំណាំគម្របដីរួមមាន៖

- ការពារដី និងកាត់បន្ថយហានិភ័យនៃសំណឹកដី
- ធ្វើឱ្យប្រសើរឡើងនូវលក្ខណៈរូបសាស្ត្រដីដោយធ្វើកែលម្អរចនាសម្ព័ន្ធដី គ្រាប់ដី(អាហ្គ្រីហ្គេតដី) និងបង្កើតរន្ធដី
- បង្កើនកម្រិតជ្រាបទឹក និងការរក្សាទឹកនៅក្នុងស្រទាប់ដី
- បង្កើនសារធាតុសរីរាង្គ និងជួយដល់ការកកើតកាបូនសរីរាង្គក្នុងដី
- បង្កើនការផលិតសារធាតុចិញ្ចឹមឡើងវិញនិងស្តុកទុក
- បង្កើនសកម្មភាពមេតាបូលីសរុក្ខជាតិ(រុក្ខជាតិលូតលាស់លឿន និងប្រើប្រាស់សារធាតុចិញ្ចឹមប្រកបដោយប្រសិទ្ធភាព) និងការផលិតសារធាតុជីវសាស្ត្រសំខាន់ៗ
- ធ្វើឱ្យសកម្មភាព និងតុល្យភាពជីវសាស្ត្ររបស់ដីកាន់តែប្រសើរ
- បង្កើនភាពធន់ទៅនឹងសត្វល្អិតចង្រៃ ជំងឺ និងណេម៉ាតូត
- បង្កើនការទប់ស្កាត់ការដុះលូតលាស់របស់ស្មៅចង្រៃ
- ជម្រុញការផលិតមេតាបូលីសបន្ទាប់បន្សំសម្រាប់ការពារដំណាំ




©Rama Sry, Rovieng



គ្រួសារ

# ស្មៅ / Poaceae

©CARDEC, Kampong Cham




# ស្មៅម៉ូឡាតូ 2
# Brachiaria mulato II









## អត្តសញ្ញាណ

| | |
|---|---|
| ឈ្មោះទូទៅ | ម៉ូឡាតូ២ |
| ឈ្មោះវិទ្យាសាស្ត្រ | ***Brachiaria mulato II*** |
| គ្រួសារ | **Poaceae** |

## លក្ខណៈរូបសាស្ត្រ

| | |
|---|---|
| កម្ពស់ | ១ ២០០ ស.ម |
| ប្រព័ន្ធឫស | ឫសយោង |
| ទម្ងន់១ ០០០គ្រាប់ | ២-៣ ក្រាម |
| ទំហំគ្រាប់ | ២,៥ ទៅ ៣,៥ ម.ម |
| អំបូរស្មៅរយៈពេលវែង | > ៥ ឆ្នាំ |
| របបទឹកភ្លៀង | ៧០០-១ ៦០០ ម.ម/ឆ្នាំ |
| ភាពប្រកាន់រដូវ | ប្រកាន់រដូវ |
| ជីវម៉ាសស្រស់ | ២០ តោន/ហ.ត (ដីមានជីជាតិទាប)<br>៧៥ តោន/ហ.ត (ដីមានជីជាតិខ្ពស់) |
| ជីវម៉ាសស្ងួត | ៤ to ៦ តោន/ហ.ត (ដីមានជីជាតិទាប)<br>១២ to ១៥ តោន/ហ.ត (ដីមានជីជាតិខ្ពស់) |

## ការដាំដុះ

| | |
|---|---|
| ពេលវេលាដាំដុះ | ដើមរដូវវស្សា |
| ការដាំជាជួរដោយម៉ាស៊ីន | ៨-១២ គ.ក្រ/ហ.ត |
| គម្លាតជួរដាំដោយម៉ាស៊ីន | ១៧-៣៤ ស.ម |
| ការដាំដោយដៃ | ៨-១២ គ.ក្រ/ហ.ត |
| គម្លាតជួរដាំដោយដៃ | ២០ ស.ម |
| ការព្រោះ | ១២-១៥ គ.ក្រ/ហ.ត |

## ដី និងទឹក

ការទប់ស្កាត់សំណឹកដី

ភាពធន់នឹងគ្រោះរាំងស្ងួត

ការសម្របខ្លួនទៅនឹងដីមានជីជាតិទាប

ការសម្របខ្លួនទៅនឹងដីលិចទឹក

ការសម្របខ្លួនទៅនឹងដីខ្មៅ (ដីអាល់កាឡាំង)

## សារជាតុចិញ្ចឹម

| | |
|---|---|
| អាសូត(សារជាតុស្ងួត) | ១,៥ ទៅ ៣,៥% |
| ផូស្វ័រ (សារជាតុស្ងួត) | ០,១០ ទៅ ០,៣០% |
| ប៉ូតាស្យូម (សារជាតុស្ងួត) | ០,៥ ទៅ ១,៥% |

## ការណែនាំ

អត្ថប្រយោជន៍៖ ផលិតជាចំណីសត្វបានច្រើន ផ្តល់សារជាតុចិញ្ចឹមល្អ ធន់នឹងគ្រោះរាំងស្ងួត។ សម្របខ្លួនបានល្អទៅនឹងប្រភេទដីផ្សេងៗគ្នា ចាប់ពីដីខ្សាច់រហូតដល់ដីអាល់កាឡាំង នៅស្រុករតនមណ្ឌល(ខេត្តបាត់ដំបង)។ ធន់ទ្រាំខ្លាំងទៅនឹងការស៊ីរបស់សត្វពាហណៈ។

ចំណុចគួរយកចិត្តទុកដាក់៖ ផ្តល់ទិន្នផលគ្រាប់ពូជទាបបើប្រៀបធៀបជាមួយ ស្មៅរូស្ស៊ី (ruzi) ស្មៅប្រីសាន់តា(B. brizantha) និង ស្មៅដេកាំបេន(B. decumbens)។ វាត្រូវការដីមានជីជាតិល្អដើម្បីទទួលបានទិន្នផលខ្ពស់។ វាដុះឈរត្រង់ ហើយមិនគ្របដណ្តប់លើផ្ទៃដីទាំងស្រុងទេ ខុសពីស្មៅរូស្ស៊ី(B. ruziziensis)។




# ស្មៅរូស៊ី
# Brachiaria ruziziensis









## អត្តសញ្ញាណ

| | |
|---|---|
| ឈ្មោះទូទៅ | ស្មៅរូស្ស៊ី |
| ឈ្មោះវិទ្យាសាស្ត្រ | ***Brachiaria ruziziensis*** |
| គ្រួសារ | ***Poaceae*** |

## លក្ខណៈរូបសាស្ត្រ

| | |
|---|---|
| កម្ពស់ | ១២០ ស.ម |
| ប្រព័ន្ធឫស | ឫសរយាង> ២៥០ ស.ម |
| ទម្ងន់១ ០០០គ្រាប់ | ៤ ក្រាម |
| ទំហំគ្រាប់ពូជ | ៣ ម.ម |
| អំបូរស្មៅរយៈពេលវែង | > ៥ ឆ្នាំ |
| របបទឹកភ្លៀង | ៨០០ - ១ ៨០០ ម.ម/ឆ្នាំ |
| ភាពប្រកាន់រដូវ | ប្រកាន់រដូវ |
| ជីវម៉ាសស្រស់ | ៣៥-៦០ តោន/ហ.ត ( ដីមានជីជាតិទាប )<br>៨០ តោន/ហ.ត ( ដីមានជីជាតិខ្ពស់ ) |
| ជីវម៉ាសស្ងួត | ៧-១២ តោន/ហ.ត ( ដីមានជីជាតិទាប )<br>១៦ តោន/ហ.ត ( ដីមានជីជាតិខ្ពស់ ) |

## ការដាំដុះ

| | |
|---|---|
| ពេលវេលាដាំដុះ | ដើមរដូវវស្សាឬបន្ទាប់ពីដំណាំចម្បង |
| ការដាំជាជួរដោយម៉ាស៊ីន | ៨-១២ គ.ក្រ/ហ.ត |
| គម្លាតជួរដាំដោយម៉ាស៊ីន | ១៧-២២ ស.ម |
| ការដាំដោយដៃ | ១០-១២ គ.ក្រ/ហ.ត |
| គម្លាតជួរដាំដោយដៃ | ២០ ស.ម |
| ការព្រោះ | ១២-១៥ គ.ក្រ/ហ.ត |

## ដី & ទឹក

ការទប់ស្កាត់សំណឹកដី

ភាពធន់នឹងគ្រោះរាំងស្ងួត

ការសម្របខ្លួនទៅនឹងដីមានជីជាតិទាប

ការសម្របខ្លួនទៅនឹងដីលិចទឹក

ការសម្របខ្លួនទៅនឹងដីខ្មៅ ( ដីអាល់កាឡាំង )



## សារជាតុចិញ្ចឹម

| | |
|---|---|
| អាសូត( សារជាតុស្ងួត ) | ១,៥ ទៅ ៣,៥% |
| ផូស្វ័រ ( សារជាតុស្ងួត ) | ០,១០ ទៅ ០,៣០% |
| ប៉ូតាស្យូម ( សារជាតុស្ងួត ) | ០,៥ ទៅ ១,៥% |

## ការណែនាំ

**អត្ថប្រយោជន៍៖** ជាប្រភពចំណីសត្វដែលមានគុណភាពខ្ពស់។ ជួយកែលម្អរចនាសម្ព័ន្ធដី (ការប្រមូលផ្តុំភាគល្អិតដី) តាមរយៈប្រព័ន្ធឫសរបស់វា។ ស្មៅរូស្ស៊ីមានសមត្ថភាពសម្របខ្លួនបានល្អ ប៉ុន្តែវាធន់នឹងគ្រោះរាំងស្ងួតតិចជាង B. decumbens, B. brizantha និង B. mullato។ ស្មៅរូស្ស៊ីសម្របខ្លួនបានល្អទៅនឹងតំបន់ក្សេត្របរិស្ថាននៅភាគឦសាននៃប្រទេសកម្ពុជាដែលមានរយៈកម្ពស់មធ្យម និងមាន របបទឹកភ្លៀងខ្ពស់។

**ចំណុចយកចិត្តទុកដាក់៖** ស្មៅរូស្ស៊ីមិនអាចដុះលូតលាស់លើដីលិចទឹកបានទេ។ វាក៏អាចត្រូវបានដាំជាដំណាំគម្របដីមុនដាំដំណាំចម្បង (សណ្តែកសៀង) ឬក្រោយដំណាំចម្បង (ពោត ឬដំឡូងមី)ផងដែរ។ វាជាការល្អក្នុងការដាំលាយគ្នារវាងស្មៅរូស្ស៊ីនិងស្មៅអំបូរសណ្តែកផ្សេងទៀតដើម្បីកាត់បន្ថយការបាត់បង់សារធាតុអាសូត។ ស្មៅរូស្ស៊ីអាចដាំលាយជាមួយពពួកមេលែត, ស្ទីឡូ, ចង្រ្កងស្វាស្លឹកតូច, សណ្តែកអង្រែ ។ល។




# ស្មៅជើងក្រាស់ដើមខ្ពស់
## *Eleusine coracana*









## អត្តសញ្ញាណ

| | |
|---|---|
| ឈ្មោះទូទៅ | ស្មៅជើងក្រាស់ដើមខ្ពស់ |
| ឈ្មោះវិទ្យាសាស្ត្រ | ***Eleusine coracana*** |
| គ្រួសារ | **Poaceae** |

## លក្ខណៈរូបសាស្ត្រ

| | |
|---|---|
| កម្ពស់ | ១២០-១៥០ ស.ម |
| ប្រព័ន្ធឫស | ១៥០-២០០ ស.ម |
| ទម្ងន់១ ០០០គ្រាប់ | ៥,៦ ក្រាម |
| ទំហំគ្រាប់ពូជ | ១,៥ ម.ម |
| អំបូរស្មៅរយៈពេលខ្លី | ១១៥ ថ្ងៃ |
| របបទឹកភ្លៀង | ៦០០ ទៅ > ២ ០០០ ម.ម/ឆ្នាំ |
| ភាពប្រកាន់រដូវ | មិនប្រកាន់រដូវ |
| ជីវម៉ាស់ស្រស់ | ១៥-៣០ តោន/ហ.ត (ដីមានជីជាតិទាប)<br>៣០-៤០ តោន/ហ.ត (ដីមានជីជាតិខ្ពស់) |
| ជីវម៉ាស់ស្ងួត | ៣-៧ តោន/ហ.ត (ដីមានជីជាតិទាប)<br>៧-១២ តោន/ហ.ត (ដីមានជីជាតិខ្ពស់) |

## ការដាំដុះ

| | |
|---|---|
| ពេលវេលាដាំដុះ | ដើមរដូវវស្សា |
| ការដាំជាជួរដោយម៉ាស៊ីន | ៦-៨ គ.ក្រ/ហ.ត |
| គម្លាតជួរដាំដោយម៉ាស៊ីន | ១៧-៣៤ ស.ម |
| ការដាំដោយដៃ | ៦-៨ គ.ក្រ/ហ.ត |
| គម្លាតជួរដាំដោយដៃ | ២៥-៣៥ ស.ម |
| ការព្រោះ | ៨-១០ គ.ក្រ/ហ.ត |

## ដី & ទឹក

ការទប់ស្កាត់សំណឹកដី
ភាពធន់នឹងគ្រោះរាំងស្ងួត
ការសម្របខ្លួនទៅនឹងដីមានជីជាតិទាប
ការសម្របខ្លួនទៅនឹងដីជាំទឹក
ការសម្របខ្លួនទៅនឹងដីខ្មៅ (ដីអាល់កាឡាំង)



## សារធាតុចិញ្ចឹម

| | |
|---|---|
| អាសូត (សារធាតុស្ងួត) | ១,២ ទៅ ២,៥% |
| ផូស្វ័រ (សារធាតុស្ងួត) | ០,២ ទៅ ០,៤៥% |
| ប៉ូតាស្យូម (សារធាតុស្ងួត) | ១,០ ទៅ ២,០% |

## ការណែនាំ

អត្ថប្រយោជន៍៖ ប្រភេទស្មៅដ៏ល្អបំផុតមួយសម្រាប់កែលម្អរចនាសម្ព័ន្ធដីតាមរយៈប្រព័ន្ធឫសរយាងដែលដុះយ៉ាងជ្រៅរបស់វា។ គ្រាប់របស់វាត្រូវបានប្រមូលផល និងប្រើប្រាស់សម្រាប់មនុស្ស ឬសត្វដោយសារមានកម្រិតអាហារូបត្ថម្ភខ្ពស់។ វាផលិតជីវម៉ាសបានច្រើនក្នុងរយៈពេលខ្លី មានឱជារស និងមានសារធាតុចិញ្ចឹមខ្ពស់។ វាមានសមត្ថភាពខ្ពស់ក្នុងការបញ្ចេញអាសូតក្នុងបរិមាណដ៏ច្រើន ដែលជាចំណុចពិសេសមួយសម្រាប់ប្រភេទស្មៅនេះ។

ចំណុចយកចិត្តទុកដាក់៖ ដុះលូតលាស់ល្អខ្លាំង បើសិនជាដាំនៅដើមរដូវវស្សា។




# មីលេត
## Pennisetum glaucum









## អត្តសញ្ញាណ

| | |
|---|---|
| ឈ្មោះទូទៅ | មីលែត |
| ឈ្មោះវិទ្យាសាស្ត្រ | ***Pennisetum glaucum*** |
| គ្រួសារ | ***Poaceae*** |

## លក្ខណៈរូបសាស្ត្រ

| | |
|---|---|
| កម្ពស់ | ២០០ ស.ម |
| ប្រព័ន្ធឫស | ២៥០ ស.ម |
| ទម្ងន់១ ០០០គ្រាប់ | ១១,៦ ក្រាម |
| ទំហំគ្រាប់ពូជ | ៣ ម.ម |
| ពេលវេលាចេញផ្កា \| អំបូរស្មៅរយៈពេលខ្លី | ៤៥-៥៥ ថ្ងៃ\| ១០០-១១០ ថ្ងៃ |
| របបទឹកភ្លៀង | ៣០០ - ១ ៦០០ ម.ម/ ឆ្នាំ |
| ភាពប្រកាន់រដូវ | ប្រកាន់រដូវ |
| ជីរម៉ាស់ស្រស់ | ៥-២០ តោន/ហ.ត (ដីមានជីជាតិទាប)<br>៣០-៥០ តោន/ហ.ត (ដីមានជីជាតិបង្គួរ) |
| ជីរម៉ាស់ស្ងួត | ១-៤ តោន/ហ.ត (ដីមានជីជាតិទាប)<br>៦ -១២ តោន/ហ.ត (ដីមានជីជាតិបង្គួរ) |

## ការដាំដុះ

| | |
|---|---|
| ពេលវេលាដាំដុះ | ដើមរដូវវស្សា ឬ បន្ទាប់ពីដំណាំចម្បង |
| ការដាំជាជួរដោយម៉ាស៊ីន | ៨-១០ គ.ក្រ/ហ.ត |
| គម្លាតជួរដាំដោយម៉ាស៊ីន | ១៧-៤០ ស.ម |
| ការដាំដោយដៃ | ១០-១២ គ.ក្រ/ហ.ត |
| គម្លាតជួរដាំដោយដៃ | ២០-៤០ ស.ម |
| ការព្រោះ | ១២-១៥ គ.ក្រ/ហ.ត |

## ដី & ទឹក

ការទប់ស្កាត់សំណឹកដី
ភាពធន់នឹងគ្រោះរាំងស្ងួត
ការសម្របខ្លួនទៅនឹងដីមានជីជាតិទាប
ការសម្របខ្លួនទៅនឹងដីជាំទឹក
ការសម្របខ្លួនទៅនឹងដីខ្សាច់



## សារធាតុចិញ្ចឹម

| | |
|---|---|
| អាសូត (សារធាតុស្ងួត) | ០,៤ ទៅ៣,៤% |
| ផូស្វ័រ (សារធាតុស្ងួត) | ០,១៣ ទៅ ០,២៩% |
| ប៉ូតាស្យូម (សារធាតុស្ងួត) | ១,០ ទៅ ៣,៨% |

## ការណែនាំ

**អត្ថប្រយោជន៍៖** មីលែតជាជម្រើសស្មៅល្អបំផុតមួយសម្រាប់ដាំដុះមុននឹងដាំដំឡូងមីដើម្បីគ្រប់គ្រងស្មៅ និងស្តារឡើងវិញនូវសារធាតុប៉ូតាស្យូម។ វាមានសមត្ថភាពខ្ពស់ក្នុងការកកើតសារធាតុប៉ូតាស្យូមឡើងវិញ (៦០-១៥០ គ.ក្រ/ហ.ត)។

**ចំណុចយកចិត្តទុកដាក់៖** គ្រាប់ពូជរបស់វាត្រូវការពេលចន្លោះពី៧០ ទៅ ៧៥ថ្ងៃទើបចាស់ល្អសម្រាប់ទុកដាំដុះបន្តបាន។ ត្រូវពិចារណាចំណុចនេះមុនជ្រើសរើសប្រើមីលែតជាដំណាំគម្របដីមុនពេលដាំដំណាំចម្បង។




# ស្គួយ
# Sorghum bicolor









## អត្តសញ្ញាណ

| | |
|---|---|
| ឈ្មោះទូទៅ | ស្កូយ |
| ឈ្មោះវិទ្យាសាស្ត្រ | ***Sorghum bicolor* cv. *Pool preto*** |
| គ្រួសារ | ***Poaceae*** |

## លក្ខណៈរូបសាស្ត្រ

| | |
|---|---|
| កម្ពស់ | ១០០-៥០០ ស.ម |
| ប្រព័ន្ធឫស | ឫសរយាង |
| ទម្ងន់១ ០០០គ្រាប់ | ២៦,៣ ក្រាម |
| ទំហំគ្រាប់ពូជ | ៤,៥ ម.ម |
| ពេលវេលាចេញផ្កា \| អំបូរស្មៅរយៈពេលខ្លី | ៦០ ថ្ងៃ \| ១៥០ ថ្ងៃ |
| របបទឹកភ្លៀង | ៣០០-១ ៨០០ ម.ម/ ឆ្នាំ |
| ភាពប្រកាន់រដូវ | មិនប្រកាន់រដូវ |
| ជីវម៉ាស់ស្រស់ | ១៥-៣៥ តោន/ហ.ត (ដីមានជីជាតិទាប) |
| | ៩០ តោន/ហ.ត (ដីមានជីជាតិបង្គួរ) |
| ជីវម៉ាស់ស្ងួត | ៣-៧ តោន/ហ.ត (ដីមានជីជាតិទាប) |
| | ១៨ តោន/ហ.ត (ដីមានជីជាតិបង្គួរ) |

## ការដាំដុះ

| | |
|---|---|
| ពេលវេលាដាំដុះ | ដើមរដូវវស្សា ឬ បន្ទាប់ពីដំណាំចម្បង |
| ការដាំជាជួរដោយម៉ាស៊ីន | ១៥-២០ គ.ក្រ/ហ.ត |
| គម្លាតជួរដាំដោយម៉ាស៊ីន | ២២-៦០ ស.ម |
| ការដាំដោយដៃ | ១៥-២០ គ.ក្រ/ហ.ត |
| គម្លាតជួរដាំដោយដៃ | ៥០-៦០ ស.ម |
| ការព្រោះ | ២០-២៥ គ.ក្រ/ហ.ត |

## ដី & ទឹក

- ការទប់ស្កាត់សំណឹកដី
- ភាពធន់នឹងគ្រោះរាំងស្ងួត
- ការសម្របខ្លួនទៅនឹងដីមានជីជាតិទាប
- ការសម្របខ្លួនទៅនឹងដីជាំទឹក
- ការសម្របខ្លួនទៅនឹងដីខ្មៅ (ដីអាល់កាឡាំង)

## សារធាតុចិញ្ចឹម

| | |
|---|---|
| អាសូត (សារធាតុស្ងួត) | ១,០ ទៅ ២,០% |
| ផូស្វ័រ (សារធាតុស្ងួត) | ០,១ ទៅ ០,៤% |
| ប៉ូតាស្យូម (សារធាតុស្ងួត) | ១,៥ ទៅ ៣,៥% |

## ការណែនាំ

អត្ថប្រយោជន៍: ស្កូយ(ពូជ Pool preto)មានប្រព័ន្ធឫសជ្រៅ ធន់នឹងគ្រោះរាំងស្ងួត និងអាចដុះលូតលាស់ឆ្លងរដូវប្រាំងបាន។ វាក៏ផ្តល់អត្ថប្រយោជន៍យ៉ាងសម្បូរបែប ដូចជា ជួយដល់ការកកើតសារធាតុចិញ្ចឹមឡើងវិញដែលហូរចូលទៅក្នុងស្រទាប់ដីខាងក្រោម។ ការផលិតជីវម៉ាសដ៏ច្រើនបានជួយទប់ស្កាត់សំណឹកដី ការស្រូបយកសារធាតុផូស្វ័រ(P) និងប៉ូតាស្យូម(K)។ វាជួយគ្រប់គ្រងស្មៅចង្រៃបានល្អដោយសារឥទ្ធិពលនៃសារធាតុអាឡេឡូប៉ាទីដែលបញ្ចេញពីដងដើមរបស់វា។

ចំណុចយកចិត្តទុកដាក់៖ មានភាពលំបាកក្នុងការស្វែងរកម៉ាស៊ីនច្រូតកាត់ក្នុងពេលប្រមូលផល។ ស្កូយមានភាពធន់ខ្លាំងទៅនឹងការលិចទឹក ដូច្នេះសូមគិតគូរពីចំណុចនេះនៅពេលប្រើប្រាស់វានៅក្នុងប្រព័ន្ធដាំដុះដំណាំស្រូវ។



គ្រួសារ

# សណ្តែក/ **Fabaceae**

©Pheng Phomrim




# សណ្តែកដីព្រៃ
# Arachis repens









## អត្តសញ្ញាណ

| | |
|---|---|
| ឈ្មោះទូទៅ | សណ្តែកដីព្រៃ |
| ឈ្មោះវិទ្យាសាស្ត្រ | ***Arachis repens*** |
| គ្រួសារ | ***Fabaceae*** |

## លក្ខណៈរូបសាស្ត្រ

| | |
|---|---|
| កម្ពស់ | រហូតដល់ ១៥ ស.ម |
| ប្រព័ន្ធឫស | ១០០ ស.ម |
| រចនាសម្ព័ន្ធផ្នែកខាងលើដី | ប្រភេទវារ |
| អំបូរសណ្តែករយៈពេលវែង | > ៥ ឆ្នាំ |
| របបទឹកភ្លៀង | ១ ២០០ - ២ ០០០ ម.ម/ឆ្នាំ |
| ភាពប្រកាន់រដូវ | មិនប្រកាន់រដូវ |
| ជីវម៉ាស់ស្រស់ | ៦ តោន/ហ.ត (ដីខ្សោះជីជាតិ)<br>២៤ តោន/ហ.ត (ដីមានជីជាតិល្អ) |
| ជីវម៉ាស់ស្ងួត | ១,៥ តោន/ហ.ត (ដីខ្សោះជីជាតិ)<br>៦ តោន/ហ.ត (ដីមានជីជាតិល្អ) |

## ការដាំដុះ

| | |
|---|---|
| ពេលវេលាដាំដុះ | ដើមរដូវវស្សា |
| ការកាត់ | ៤ ដើម/ម² |
| ការដាំ | ៥០ × ៥០ ស.ម |

## ដី & ទឹក

- ការទប់ស្កាត់សំណឹកដី
- ភាពធន់នឹងគ្រោះរាំងស្ងួត
- ការសម្របខ្លួនទៅនឹងដីមានជីជាតិទាប
- ការសម្របខ្លួនទៅនឹងដីជាំទឹក
- ការសម្របខ្លួនទៅនឹងដីខ្សោយ (ដីអាល់កាឡាំង)

## សារធាតុចិញ្ចឹម

| | |
|---|---|
| អាសូត (សារធាតុស្ងួត) | ២,០ ទៅ ៣,៥% |
| ផូស្វ័រ (សារធាតុស្ងួត) | ០,៣ ទៅ ០,៧% |
| ប៉ូតាស្យូម (សារធាតុស្ងួត) | ១,០ ទៅ ២,៥% |

## ការណែនាំ

**អត្ថប្រយោជន៍៖** សណ្តែកដីព្រៃគឺជាប្រភេទដំណាំគម្របដីដែលសមស្របបំផុតមួយក្នុងការគ្រប់គ្រងស្មៅចង្រៃក្នុងប្រព័ន្ធដាំដុះដំណាំមៀនប៉ៃលិន ដោយយើងគ្រាន់តែសម្អាតស្មៅនៅជុំវិញគល់មៀនប៉ៃលិនតែប៉ុណ្ណោះ។ សណ្តែកដីព្រៃគឺដុះរីងរៃក្នុងរដូវប្រាំង និងចាប់ផ្តើមដុះលូតលាស់សារឡើងវិញនៅពេលមានភ្លៀងធ្លាក់លើកដំបូង។ វាជួយទប់ស្កាត់សំណឹកដី និងមានភាពធន់ទ្រាំខ្ពស់នឹងគ្រោះរាំងស្ងួត។

**ចំណុចយកចិត្តទុកដាក់៖** ត្រូវការពេលវេលាក្នុងការដុះលូតលាស់គ្របដណ្តប់ឱ្យពេញផ្ទៃដី ហើយដាំដោយប្រើដើមរបស់វា។ ត្រូវប្រុងប្រយ័ត្នចំពោះការប្រកួតប្រជែងទឹក និងសារធាតុចិញ្ចឹមជាមួយឈើហូបផ្លែនៅឆ្នាំដំបូង។ នៅឆ្នាំទី១ គួរតែដាំចង្រ្កងស្វាស្លឹកតូចនៅចន្លោះជួរដំណាំមៀនប៉ៃលិន ឬឈើហូបផ្លែផ្សេងទៀត ហើយដាំសណ្តែកដីព្រៃនៅឆ្នាំទី២។




# សណ្ដែកអង្រែ
# Cajanus cajan









## អត្តសញ្ញាណ

| | |
|---|---|
| ឈ្មោះទូទៅ | សណ្ដែកអង្រៃ |
| ឈ្មោះវិទ្យាសាស្ត្រ | ***Cajanus cajan*** |
| គ្រួសារ | ***Fabaceae*** |

## លក្ខណៈរូបសាស្ត្រ

| | |
|---|---|
| កម្ពស់ | ១០០-៤០០ ស.ម |
| ប្រព័ន្ធឫស | ឫសកែវ និងឫសរយាង |
| ទម្ងន់១ ០០០គ្រាប់ | ១២៦,៧ ក្រាម |
| ទំហំគ្រាប់ពូជ | ៣ ម.ម |
| អំបូរសណ្ដែករយៈពេលវែង | ២ ឆ្នាំ |
| របបទឹកភ្លៀង | ៣០០-២ ០០០ ម.ម/ឆ្នាំ |
| ភាពប្រកាន់រដូវ | ប្រកាន់រដូវ(អាស្រ័យលើប្រភេទពូជ) |
| ជីរ៉ែម៉ាស់ស្រស់ | ១៥ តោន/ហ.ត (ដីមានជីជាតិទាប)<br>១៥-៣៥ តោន/ហ.ត (ដីមានជីជាតិបង្គួរ ទៅ ល្អ) |
| ជីរ៉ែម៉ាស់ស្ងួត | ៣ តោន/ហត(ដីមានជីជាតិទាប)<br>៣-៧ តោន/ហ.ត (ដីមានជីជាតិបង្គួរ ទៅ ល្អ) |

## ការដាំដុះ

| | |
|---|---|
| ពេលវេលាដាំដុះ | ដើមរដូវវស្សា ឬ ដាំចន្លោះដំណាំពោត |
| ការដាំជាជួរដោយម៉ាស៊ីន | ២០-៣០ គ.ក្រ/ហ.ត |
| គម្លាតជួរដាំដោយម៉ាស៊ីន | ៣៤-៨០ ស.ម |
| ការដាំដោយដៃ | ២០-៣០ គ.ក្រ/ហ.ត |
| គម្លាតជួរដាំដោយដៃ | ៤០-៨០ ស.ម |
| ការព្រោះ | ៤០-៥០ គ.ក្រ/ហ.ត |

## ដី & ទឹក

- ការទប់ស្កាត់សំណឹកដី
- ភាពធន់នឹងគ្រោះរាំងស្ងួត
- ការសម្របខ្លួនទៅនឹងដីមានជីជាតិទាប
- ការសម្របខ្លួនទៅនឹងដីជាំទឹក
- ការសម្របខ្លួនទៅនឹងដីខ្សោ (ដីអាល់កាឡាំង)

## សារធាតុចិញ្ចឹម

| | |
|---|---|
| អាសូត (សារធាតុស្ងួត) | ២,០ ទៅ ៣,៥% |
| ផូស្វ័រ (សារធាតុស្ងួត) | ០,៣ ទៅ ០,៦% |
| ប៉ូតាស្យូម (សារធាតុស្ងួត) | ១,៥ ទៅ ៣,០% |

## ការណែនាំ

អត្ថប្រយោជន៍៖ សណ្ដែកអង្រៃផ្ដល់សារចិញ្ចឹមខ្ពស់ ហើយមានគុណសម្បត្តិល្អដូចជា មានសមត្ថភាពក្នុងការចាប់យកសារធាតុអាសូត ទប់ស្កាត់សំណឹកដី និងកែលម្អរចនាសម្ព័ន្ធនិងគុណភាពដីតាមរយៈប្រព័ន្ធឫសរបស់វា។ សណ្ដែកអង្រៃជាប្រភេទដំណាំដែលធន់នឹងគ្រោះរាំងស្ងួត ហើយវាក៏ត្រូវបានគេប្រើជាប្រភពចំណីសត្វដែលមានគុណភាពល្អផងដែរ។ អ្នកក៏អាចកាត់សណ្ដែកអង្រៃបន្ទាប់ពីប្រមូលផលរួច ហើយវានឹងដុះសារជាថ្មី។ វាមានសមត្ថភាពខ្ពស់ក្នុងការគ្រប់គ្រងស្មៅចង្រៃ។

ចំណុចយកចិត្តទុកដាក់៖ វាមានពូជច្រើនប្រភេទដូចជា ពូជតឿ ខ្ពស់ ប្រកាន់រដូវ មិនប្រកាន់រដូវ ជាដើម។ដូច្នេះអ្នកត្រូវជ្រើសរើសប្រភេទពូជដែលសមស្របនឹងតម្រូវការរបស់អ្នក(កែលម្អដី, ជាដំណាំចន្លោះ...)។



# សង់ត្រូ
# Centrosema pascuorum









## អត្តសញ្ញាណ

| | |
|---|---|
| ឈ្មោះទូទៅ | សង់ត្រូ |
| ឈ្មោះវិទ្យាសាស្ត្រ | ***Centrosema pascuorum cv. Cavalcade*** |
| គ្រួសារ | **Fabaceae** |

## លក្ខណៈរូបសាស្ត្រ

| | |
|---|---|
| កម្ពស់ | ៥០០ ស.ម |
| ប្រព័ន្ធឫស | ១៥០-២៥០ ស.ម |
| ទម្ងន់១ ០០០គ្រាប់ | ២១,៥ ក្រាម |
| ទំហំគ្រាប់ពូជ | ២,៥ ទៅ ៤ ម.ម |
| អំបូរសណ្តែករយៈពេលវែង | ២-៣ឆ្នាំ |
| របបទឹកភ្លៀង | ៧០០-១ ៦០០ ម.ម/ឆ្នាំ |
| ភាពប្រកាន់រដូវ | ប្រកាន់រដូវ |
| ជីវម៉ាស់ស្រស់ | ២០-៨៥ តោន/ហ.ត |
| ជីវម៉ាស់ស្ងួត | ៤-១២ តោន/ហ.ត |

## ការដាំដុះ

| | |
|---|---|
| ពេលវេលាដាំដុះ | ឧសភា - កញ្ញា |
| ការដាំជាជួរដោយម៉ាស៊ីន | ៨-១០ គ.ក្រ/ហ.ត |
| គម្លាតជួរដាំដោយម៉ាស៊ីន | ២២-៤៤ ស.ម |
| ការដាំដោយដៃ | ១០-១២ គ.ក្រ/ហ.ត |
| គម្លាតជួរដាំដោយដៃ | ៤០-៥០ ស.ម |
| ការព្រោះ | ១៥ គ.ក្រ/ហ.ត |

## ដី & ទឹក

ការទប់ស្កាត់សំណឹកដី

ភាពធន់នឹងគ្រោះរាំងស្ងួត

ការសម្របខ្លួនទៅនឹងដីមានជីជាតិទាប

ការសម្របខ្លួនទៅនឹងដីជាំទឹក

ការសម្របខ្លួនទៅនឹងដីខ្សោ (ដីអាល់កាឡាំង)



## សារធាតុចិញ្ចឹម

| | |
|---|---|
| អាសូត (សារធាតុស្ងួត) | ១,៨ ទៅ ៣,៥% |
| ផូស្វ័រ (សារធាតុស្ងួត) | ០,២ ទៅ ០,៥% |
| ប៉ូតាស្យូម (សារធាតុស្ងួត) | ០,៧ ទៅ ២,០% |

## ការណែនាំ

អត្ថប្រយោជន៍៖ សង់ត្រូចាប់យកអាសូតពី៥០ទៅ១៥០គ.ក្រ/ហ.ត/ឆ្នាំ។ វាអាចដុះលូតលាស់ឆ្លងកាត់រដូវប្រាំងបានប្រសើរជាងប្រភេទសណ្តែកផ្សេងៗទៀត។ វាដុះលូតលាស់បានល្អនៅក្នុងប្រព័ន្ធកសិកម្មដែលមានធាតុចូលទាបនៅកម្ពុជា។ វាផ្តល់ទិន្នផលជីវម៉ាស់ខ្ពស់នៅក្នុងដីខ្សាច់មានជាតិអាស៊ីត។ ងាយស្រួលក្នុងការសាបព្រោះនៅពេលទឹកក្នុងស្រែចាប់ផ្តើមស្រក បន្ទាប់ឬមុនពេលប្រមូលផលដំណាំស្រូវ។ ងាយស្រួលក្នុងការកម្ចាត់ដោយប្រើប្រាស់រ៉ូឡូកិន។

ចំណុចយកចិត្តទុកដាក់៖ សង់ត្រូគឺមានភាពប្រកួតប្រជែងខ្ពស់ជាមួយស្មៅចង្រៃលើប្រភេទដីខ្សាច់មានជាតិអាស៊ីតខ្ពស់បើប្រៀបធៀបជាមួយប្រភេទដីផ្សេងទៀត។



# ចង្ក្រងស្វាស្លឹកធំ
# Crotalaria juncea









## អត្តសញ្ញាណ

| | |
|---|---|
| ឈ្មោះទូទៅ | ចង្រ្កងស្វាស្លឹកធំ |
| ឈ្មោះវិទ្យាសាស្ត្រ | **Crotalaria juncea** |
| គ្រួសារ | **Fabaceae** |

## លក្ខណៈរូបសាស្ត្រ

| | |
|---|---|
| កម្ពស់ | ២០០ ស.ម |
| ប្រព័ន្ធឫស | ឫសកែវ និងឫសរយាង |
| ទម្ងន់១ ០០០គ្រាប់ | ៣៥,៤ ក្រាម |
| ទំហំគ្រាប់ពូជ | ៦-7៧ ម.ម |
| ពេលវេលាចេញផ្កា \| អំបូរសណ្ដែករយៈពេល | ៤៥-៥៥ ថ្ងៃ \| ១១០ ថ្ងៃ |
| ខ្លី | ៨០០-២ ០០០ ម.ម/ឆ្នាំ |
| របបទឹកភ្លៀង | មិនប្រកាន់រដូវ |
| ភាពប្រកាន់រដូវ | ៣-១០ តោន/ហ.ត (ដីមានជីជាតិទាប) |
| ដីរម៉ាសស្រស់ | ៣០ តោន/ហ.ត (ដីមានជីជាតិខ្ពស់) |
| | ០,៥-២,០ តោន/ហ.ត (ដីមានជីជាតិទាប) |
| ដីរម៉ាស់ស្ងួត | ៦ តោន/ហ.ត (ដីមានជីជាតិខ្ពស់) |

## ការដាំដុះ

| | |
|---|---|
| ពេលវេលាដាំដុះ | ដើមរដូវវស្សា ឬបន្ទាប់ពីដំណាំប្រចាំឆ្នាំចម្បង |
| ការដាំជាជួរដោយម៉ាស៊ីន | ២០-៣០ គ.ក្រ/ហ.ត |
| គម្លាតជួរដាំដោយម៉ាស៊ីន | ២២-៤៥ ស.ម |
| ការដាំដោយដៃ | ២០-៣០ គ.ក្រ/ហ.ត |
| គម្លាតជួរដាំដោយដៃ | ២៥-៤៥ ស.ម |
| ការព្រោះ | ៣០-៣៥ គ.ក្រ/ហ.ត |

## ដី & ទឹក

ការទប់ស្កាត់សំណឹកដី

ភាពធន់នឹងគ្រោះរាំងស្ងួត

ការសម្របខ្លួនទៅនឹងដីមានជីជាតិទាប

ការសម្របខ្លួនទៅនឹងដីជាំទឹក

ការសម្របខ្លួនទៅនឹងដីខ្មៅ (ដីអាល់កាឡាំង)



## សារធាតុចិញ្ចឹម

| | |
|---|---|
| អាសូត (សារធាតុស្ងួត) | ១,១៣ ទៅ ៤,៤០% |
| ផូស្វ័រ (សារធាតុស្ងួត) | ០,០៩ ទៅ ០,៣៧% |
| ប៉ូតាស្យូម (សារធាតុស្ងួត) | ០,៥៧ ទៅ ៣,៣៧% |

## ការណែនាំ

**អត្ថប្រយោជន៍៖** មុខងារជាច្រើនត្រូវបានរកឃើញនៅពេលដាំដំណាំចង្រ្កងស្វាស្លឹកធំ ដូចជាការកែលម្អរចនាសម្ព័ន្ធដី ការផ្ដល់សារធាតុអាសូតសម្រាប់ដំណាំចម្បង និងការកាត់បន្ថយការរីករាលដាលនៃណេម៉ាតូតលើប៉ារ៉ាស៊ីតរុក្ខជាតិ។ សារធាតុអាឡេឡូប៉ាទីប៉ះពាល់ដល់រុក្ខជាតិចង្រៃជាច្រើនរួមទាំងទឹកដោះខ្លាធំ(Euphorbia heterophylla) ដែលដុះលើប្រភេទដីផ្សេងៗគ្នា។ វាទាក់ទាញខ្លាំងសម្រាប់ឃ្មុំ។ ការផលិតគ្រាប់ពូជបានច្រើនរហូតដល់ (> ១ ០០០ គ.ក្រ/ហ.ត)។

**ចំណុចយកចិត្តទុកដាក់៖** ចង្រ្កងស្វាស្លឹកធំមិនអាចដុះលូតលាស់បានល្អនៅលើដីជាំទឹកទេ។ ដូច្នេះវាជាគុណសម្បត្តិមួយក្នុងការកម្ចាត់ចង្រ្កងស្វាស្លឹកធំតាមរយៈការបញ្ចូលទឹក នៅពេលដាំវាជាដំណាំគម្របដីមុនពេលដាំដុះលើស្រែដែលមានប្រព័ន្ធស្រោចស្រព។



# ចង្ក្រងស្វាស្លឹកតូច
## Crotalaria ochroleuca









## អត្តសញ្ញាណ

| | |
|---|---|
| ឈ្មោះទូទៅ | ចង្រ្កងស្វាស្លឹកតូច |
| ឈ្មោះវិទ្យាសាស្ត្រ | ***Crotalaria ochroleuca*** |
| គ្រួសារ | **Fabaceae** |

## លក្ខណៈរូបសាស្ត្រ

| | |
|---|---|
| កម្ពស់ | ២ ៥០០ ស.ម |
| ប្រព័ន្ធឫស | ឫសកែវ និងឫសរយាង |
| ទម្ងន់១ ០០០គ្រាប់ | ៨,២ g |
| ទំហំគ្រាប់ពូជ | ១,៥-២ ម.ម |
| ពេលវេលាចេញផ្កា \| អំបូរសណ្តែករយៈពេលខ្លី | ៦៥ ថ្ងៃ \| អាយុកាលខ្លី |
| របបទឹកភ្លៀង | ៨០០-២ ០០០ ម.ម/ឆ្នាំ |
| ភាពប្រកាន់រដូវ | ប្រកាន់រដូវ |
| ជីវម៉ាស់ស្រស់ | ៣០-៥០ តោន/ហ.ត |
| ជីវម៉ាស់ស្ងួត | ៧-១២ តោន/ហ.ត |

## ការដាំដុះ

| | |
|---|---|
| ពេលវេលាដាំដុះ | ខែឧសភា - ពាក់កណ្តាលខែកញ្ញា |
| ការដាំជាជួរដោយម៉ាស៊ីន | ៦-៨ គ.ក្រ/ហ.ត |
| គម្លាតជួរដាំដោយម៉ាស៊ីន | ២២-៤៤ ស.ម |
| ការដាំដោយដៃ | ៨-១០ គ.ក្រ/ហ.ត |
| គម្លាតជួរដាំដោយដៃ | ២៥-៤៥ ស.ម |
| ការព្រោះ | ១២-១៥ គ.ក្រ/ហ.ត |

## ដី & ទឹក

ការទប់ស្កាត់សំណឹកដី

ភាពធន់នឹងគ្រោះរាំងស្ងួត

ការសម្របខ្លួនទៅនឹងដីមានជីជាតិទាប

ការសម្របខ្លួនទៅនឹងដីជាំទឹក

ការសម្របខ្លួនទៅនឹងដីខ្មៅ (ដីអាល់កាឡាំង)



## សារធាតុចិញ្ចឹម

| | |
|---|---|
| អាសូត (សារធាតុស្ងួត) | ០,៨ ទៅ ១,២៥% |
| ផូស្វ័រ (សារធាតុស្ងួត) | ០,០៦ ទៅ ០,០៨% |
| ប៉ូតាស្យូម (សារធាតុស្ងួត) | ០,៥០ ទៅ ០,៨៧% |

## ការណែនាំ

**អត្ថប្រយោជន៍៖** ចង្រ្កងស្វាស្លឹកតូចផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដល់ដី ផលិតជីវម៉ាសបានច្រើន និងផ្តល់សារធាតុចិញ្ចឹមឡើងវិញ។ វាជួយដល់ការទប់ស្កាត់សំណឹកដី កែលម្អរចនាសម្ព័ន្ធដីតាមរយៈប្រព័ន្ធឫសកែវដ៏រឹងមាំដែលអាចចាក់ចូលជ្រៅទៅក្នុងដី។ វាជួយដល់ការគ្រប់គ្រងស្មៅចង្រៃ។ ផលិតកម្មគ្រាប់ពូជខ្ពស់បានរហូតដល់ (> ១ ០០០ គ.ក្រ/ហ.ត)។ វាអាចត្រូវបានកម្ចាត់បានតាមរយៈការបញ្ចូលទឹកលើស្រែដែលមានប្រព័ន្ធស្រោចស្រព។

**ចំណុចយកចិត្តទុកដាក់៖** ការលូតលាស់យឺតនៅដំណាក់កាលដំបូង។ ចំពោះការផលិតគ្រាប់ពូជ ការសាបព្រោះគួរតែធ្វើឡើងមុនពាក់កណ្តាលខែកញ្ញា។



# ពពាយស្បែក
# Dolichos lablab









## អត្តសញ្ញាណ

| | |
|---|---|
| ឈ្មោះទូទៅ | ពពាយស្បែក |
| ឈ្មោះវិទ្យាសាស្ត្រ | ***Dolichos lablab*** |
| គ្រួសារ | **Fabaceae** |

## លក្ខណៈរូបសាស្ត្រ

| | |
|---|---|
| កម្ពស់ | ១ ០០០ ស.ម |
| ប្រព័ន្ធឫស | ១៥០-២៥០ ស.ម |
| ទម្ងន់១ ០០០គ្រាប់ | ២៥៤,៩ ក្រាម |
| ទំហំគ្រាប់ពូជ | ៥-១៥ ម.ម |
| អំបូរសណ្ដែករយៈពេលខ្លី | អាយុកាលខ្លី |
| របបទឹកភ្លៀង | ៣០០-២ ០០០ ម.ម / ឆ្នាំ |
| ភាពប្រកាន់រដូវ | ប្រកាន់រដូវ |
| ជីវម៉ាស់ស្រស់ | ១៥-៣០ តោន/ហ.ត |
| ជីវម៉ាស់ស្ងួត | ៣-៧ តោន/ហ.ត |

## ការដាំដុះ

ពេលវេលាដាំដុះ

| | |
|---|---|
| ការដាំជាជួរដោយម៉ាស៊ីន | ១៥-២០ គ.ក្រ/ហ.ត |
| គម្លាតជួរដាំដោយម៉ាស៊ីន | ៤០-៥០ ស.ម |
| ការដាំដោយដៃ | ១៥-២០ គ.ក្រ/ហ.ត |
| គម្លាតជួរដាំដោយដៃ | ៦០-៨០ ស.ម |
| ការព្រោះ | ២០-២៥ គ.ក្រ/ហ.ត |

## ដី & ទឹក

ការទប់ស្កាត់សំណឹកដី

ភាពធន់នឹងគ្រោះរាំងស្ងួត

ការសម្របខ្លួនទៅនឹងដីមានជីជាតិទាប

ការសម្របខ្លួនទៅនឹងដីជាំទឹក

ការសម្របខ្លួនទៅនឹងដីខ្មៅ (ដីអាល់កាឡាំង)

## សារធាតុចិញ្ចឹម

| | |
|---|---|
| អាសូត (សារធាតុស្ងួត) | ២,០ ទៅ ៣,៥% |
| ផូស្វ័រ (សារធាតុស្ងួត) | ០,១ ទៅ ០,២% |
| ប៉ូតាស្យូម (សារធាតុស្ងួត) | ១,០ ទៅ ២,៥% |

## ការណែនាំ

អត្ថប្រយោជន៍៖ ពពាយស្បែកផ្ដល់អត្ថប្រយោជន៍ជាច្រើន ដូចជាការចាប់យកសារធាតុអាសូត ការកែលម្អសុខភាពដី ទប់ស្កាត់មិនឱ្យស្មៅដុះ ទប់ស្កាត់សំណឹកដី និងធន់នឹងគ្រោះរាំងស្ងួត។ ជួយឱ្យដីមានជីជាតិ បង្កើនជីវៈចម្រុះ និងរក្សាទឹកស្ដុកទុកក្នុងដីដែលមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការធ្វើកសិកម្មប្រកបដោយចីរភាព។

ចំណុចយកចិត្តទុកដាក់៖ វាមិនងាយស្រួលក្នុងការផលិតគ្រាប់ពូជដែលមានគុណភាពក្នុងបរិមាណច្រើន និងក្នុងតម្លៃទាបទេ។



# សណ្ដែកសៀងព្រៃ
# Neonotonia wightii









## អត្តសញ្ញាណ

| | |
|---|---|
| ឈ្មោះទូទៅ | សណ្តែកសៀងព្រៃ |
| ឈ្មោះវិទ្យាសាស្ត្រ | ***Neonotonia wightii*** |
| គ្រួសារ | **Fabaceae** |

## លក្ខណៈរូបសាស្ត្រ

| | |
|---|---|
| កម្ពស់ | ២០ ស.ម |
| ប្រព័ន្ធឫស | ឫសរយាង |
| ទម្ងន់១ ០០០គ្រាប់ | ៨-១០ ក្រាម |
| ទំហំគ្រាប់ពូជ | ២-៣ ម.ម |
| អំបូរសណ្តែករយៈពេលវែង | > ៥ ឆ្នាំ |
| របបទឹកភ្លៀង | ៦០០-១ ៦០០ ម.ម/ឆ្នាំ |
| ភាពប្រកាន់រដូវ | ប្រកាន់រដូវ |
| ជីវម៉ាស់ស្រស់ | ១៥-៥០ តោន/ហ.ត |
| ជីវម៉ាស់ស្ងួត | ៣-១០ តោន/ហ.ត |

## ការដាំដុះ

| | |
|---|---|
| ពេលវេលាដាំដុះ | ដាំចន្លោះដំណាំពោត |
| ការដាំជាជួរដោយម៉ាស៊ីន | ៨-៩ គ.ក្រ/ហ.ត |
| គម្លាតជួរដាំដោយម៉ាស៊ីន | ៤០-៦០ ស.ម |
| ការដាំដោយដៃ | ៨-៩ គ.ក្រ/ហ.ត |
| គម្លាតជួរដាំដោយដៃ | ៤០-៦០ ស.ម |
| ការព្រោះ | ១០-១២ គ.ក្រ/ហ.ត |

## ដី & ទឹក

ការទប់ស្កាត់សំណឹកដី

ភាពធន់នឹងគ្រោះរាំងស្ងួត

ការសម្របខ្លួនទៅនឹងដីមានជីជាតិទាប

ការសម្របខ្លួនទៅនឹងដីជាំទឹក

ការសម្របខ្លួនទៅនឹងដីខ្មៅ (ដីអាល់កាឡាំង)

## សារធាតុចិញ្ចឹម

| | |
|---|---|
| អាសូត (សារធាតុស្ងួត) | ២,០ ទៅ ៣,៥% |
| ផូស្វ័រ (សារធាតុស្ងួត) | ០,៣ ទៅ ០,៥% |
| ប៉ូតាស្យូម (សារធាតុស្ងួត) | ១,៥ ទៅ ៣,០% |

## ការណែនាំ

អត្ថប្រយោជន៍៖ វាជួយការពារការហូរច្រោះដី និងកាត់បន្ថយសម្ពាធស្មៅចង្រៃ។ វាអាចប្រូតធ្វើជាចំណីសត្វនៅពេលដាំនៅចន្លោះវាលស្មៅ/ពពួកសណ្តែក។ សណ្តែកសៀងព្រៃអាចជួរស្តារដីខ្សោះជីជាតិបានយ៉ាងឆាប់រហ័ស ដោយសារតែការផលិតជីវម៉ាសរបស់វា ជាចំណីសម្រាប់ជីវសាស្ត្រក្នុងដី។ វាជាអំបូរសណ្តែកដែលមានសមត្ថភាពចាប់យកសារធាតុអាសូតបានយ៉ាងល្អ។ វាដុះលូតលាស់ល្អនៅក្នុងប្រភេទដីផ្សេងៗជាច្រើន រួមមានដីមានជីជាតិទាបនិងដីអាស៊ីត ព្រមទាំងលើដីខ្មៅ-អាល់កាឡាំងក្នុងខេត្តបាត់ដំបងផងដែរ។

ចំណុចយកចិត្តទុកដាក់៖ វាមិនសូវធន់នឹងគ្រោះរាំងស្ងួតហួតហែងក្នុងរដូវប្រាំងទេ ប៉ុន្តែវាអាចបន្តដុះលូតលាស់ឡើងវិញនៅពេលមានភ្លៀងធ្លាក់ដំបូង។ វាងាយនឹងកើតជំងឺផ្សិត rhizoctonia។ វាមិនងាយស្រួលក្នុងការផលិតគ្រាប់ពូជដែលផ្តល់ទិន្នផលច្រើន និងមានគុណភាពខ្ពស់នោះទេ។



# គូឌូត្រូពិច
## Pueraria phaseoloides









## អត្តសញ្ញាណ

| | |
|---|---|
| ឈ្មោះទូទៅ | គូឌូត្រូពិច |
| ឈ្មោះវិទ្យាសាស្ត្រ | ***Pueraria phaseoloides*** |
| គ្រួសារ | **Fabaceae** |

## លក្ខណៈរូបសាស្ត្រ

| | |
|---|---|
| កម្ពស់ | ៤០ ស.ម |
| ប្រព័ន្ធឫស | ២០០ ស.ម |
| ទម្ងន់១ ០០០គ្រាប់ | ១៤,៦ ក្រាម |
| ទំហំគ្រាប់ពូជ | ៣ ម.ម |
| អំបូរសណ្តែករយៈវែង | ២-៣ ឆ្នាំ |
| របបទឹកភ្លៀង | ៨០០ ទៅ ២ ៥០០ ម.ម/ឆ្នាំ |
| ភាពប្រកាន់រដូវ | ប្រកាន់រដូវ |
| ជីវម៉ាស់ស្រស់ | ៥០ តោន/ហ.ត |
| ជីវម៉ាស់ស្ងួត | ១០ តោន/ហ.ត |

## ការដាំដុះ

| | |
|---|---|
| ពេលវេលាដាំដុះ | ដាំចន្លោះដំណាំពោត ឬក្នុងខែកញ្ញា |
| ការដាំជាជួរដោយម៉ាស៊ីន | ៨-១០ គ.ក្រ/ហ.ត |
| គម្លាតជួរដាំដោយម៉ាស៊ីន | ៥០-៦០ ស.ម |
| ការដាំដោយដៃ | ៨-១០ គ.ក្រ/ហ.ត |
| គម្លាតជួរដាំដោយដៃ | ៤០-៦០ ស.ម |
| ការព្រោះ | ១០-១២ គ.ក្រ/ហ.ត |

## ដី & ទឹក

ការទប់ស្កាត់សំណឹកដី
ភាពធន់នឹងគ្រោះរាំងស្ងួត
ការសម្របខ្លួនទៅនឹងដីមានជីជាតិទាប
ការសម្របខ្លួនទៅនឹងដីជាំទឹក
ការសម្របខ្លួនទៅនឹងដីខ្មៅ (ដីអាល់កាឡាំង)



## សារធាតុចិញ្ចឹម

| | |
|---|---|
| អាសូត (សារធាតុស្ងួត) | ២,០ ទៅ ៣,០% |
| ផូស្វ័រ (សារធាតុស្ងួត) | ០,៣ ទៅ ០,៥% |
| ប៉ូតាស្យូម (សារធាតុស្ងួត) | ០,៥ ទៅ ២,០% |

## ការណែនាំ

**អត្ថប្រយោជន៍៖** ជាបណ្តុំនៃសារធាតុអាសូតដ៏ច្រើន។ វាសម្របខ្លួនបានល្អទៅនឹងដីច្រើនប្រភេទចាប់ពីដីអាស៊ីតមានជីជាតិទាបរហូតដល់ក្រុមដីVertisolនៃខេត្តបាត់ដំបង។ ប្រព័ន្ធឫសលាតសន្ធឹងដ៏ធំទូលាយរបស់វាជួយឱ្យមានស្ថេរភាពដីនៅទីជម្រាលនិងតំបន់ដែលងាយរងនូវការហូរច្រោះ។ ដោយសារតែការផលិតជីវម៉ាសបានខ្ពស់ គូឌូត្រូពិចអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការស្តុកទុកកាបូន ដោយចាប់យកកាបូនឌីអុកស៊ីត($CO_2$)ពីបរិយាកាសហើយរក្សាទុកនៅក្នុងឫស និងជីវម៉ាស។ វាជាដំណាំគម្របដីដ៏ល្អឥតខ្ចោះសម្រាប់ប្រព័ន្ធដាំដុះដំណាំពោត។

**ចំណុចយកចិត្តទុកដាក់៖** ដើម្បីទទួលបានទិន្នផលគ្រាប់ពូជច្រើននិងគុណភាពខ្ពស់ គឺមិនមែនជារឿងងាយស្រួលនោះទេ។



# ស្នោរ
# Sesbania sesban









## អត្តសញ្ញាណ

| | |
|---|---|
| ឈ្មោះទូទៅ | ស្នោរ |
| ឈ្មោះវិទ្យាសាស្ត្រ | ***Sesbania sesban*** |
| គ្រួសារ | **Fabaceae** |

## លក្ខណៈរូបសាស្ត្រ

| | |
|---|---|
| កម្ពស់ | ៨០០ ស.ម |
| ប្រព័ន្ធឫស | ១៥០-២៥០ ស.ម |
| ទម្ងន់១ ០០០គ្រាប់ | ២៥-២៧ ក្រាម |
| ទំហំគ្រាប់ពូជ | ៣ ម.ម |
| ពេលវេលាចេញផ្កា \| អំបូរសណ្តែករយៈពេលខ្លី | ៤៥-៦៥ ថ្ងៃ \| ១១០ ថ្ងៃ |
| របបទឹកភ្លៀង | ៦០០-១ ៨០០ ម.ម/ឆ្នាំ |
| ភាពប្រកាន់រដូវ | ប្រកាន់រដូវ |
| ជីវម៉ាស់ស្រស់ | ១២ to ២៥ តោន/ហ.ត |
| ជីវម៉ាស់ស្ងួត | ៣-៧ តោន/ហ.ត |

## ការដាំដុះ

| | |
|---|---|
| ពេលវេលាដាំដុះ: | ដាំចន្លោះដំណាំពោត ឬក្នុងខែកញ្ញា |
| ការដាំជាជួរដោយម៉ាស៊ីន | ៨-១០ គ.ក្រ/ហ.ត |
| គម្លាតជួរដាំដោយម៉ាស៊ីន | ៥០-៦០ ស.ម |
| ការដាំដោយដៃ | ៨-១០ គ.ក្រ/ហ.ត |
| គម្លាតជួរដាំដោយដៃ | ៤០-៦០ ស.ម |
| ការព្រោះ: | ១០-១២ គ.ក្រ/ហ.ត |

## ដី & ទឹក

ការទប់ស្កាត់សំណឹកដី

ភាពធន់នឹងគ្រោះរាំងស្ងួត

ការសម្របខ្លួនទៅនឹងដីមានជីជាតិទាប

ការសម្របខ្លួនទៅនឹងដីជាំទឹក

ការសម្របខ្លួនទៅនឹងដីខ្មៅ (ដីអាល់កាឡាំង)

## សារធាតុចិញ្ចឹម

| | |
|---|---|
| អាសូត (សារធាតុស្ងួត) | ២,៥ ទៅ ៤,០% |
| ផូស្វ័រ (សារធាតុស្ងួត) | ០,៣ ទៅ ០,៦% |
| ប៉ូតាស្យូម (សារធាតុស្ងួត) | ១,៥ ទៅ ៣,០% |

## ការណែនាំ

**អត្ថប្រយោជន៍៖** ស្នោរគឺជាអំបូរសណ្តែកមានការលូតលាស់លឿន ចាប់យកសារធាតុអាសូត និងផលិតជីវម៉ាសបានកម្រិតខ្ពស់ក្នុងរយៈពេលដ៏ខ្លី។ វាត្រូវបានដាំដុះមុនពេលដាំដំណាំចម្បង ដើម្បីទប់ស្កាត់ស្មៅចង្រៃ ការពារដី និងកកើតសារធាតុចិញ្ចឹមឡើងវិញ។ ទំនាក់ទំនងរបស់មីក្រូសរីរាង្គក្នុងការចាប់យកសារធាតុអាសូតខ្លាំងនៅលើប្រភេទដីគ្រប់ប្រភេទ។ វាសម្របខ្លួនបានល្អទៅនឹងលក្ខខណ្ឌអាស្រ័យទឹកភ្លៀង និងដីជាំទឹក។

**ចំណុចយកចិត្តទុកដាក់៖** វាជារុក្ខជាតិដែលគ្មានប្រភពច្បាស់លាស់ ហើយផ្លែរបស់វាគឺប្រេះដើម្បីបញ្ចេញគ្រាប់ពូជ ដូច្នេះអ្នកត្រូវជ្រើសរើសពេលវេលាសមស្របណាមួយដើម្បីប្រមូលផល។ ដើមរបស់វាមានសភាពទន់ ហើយការកម្ចាត់ដោយមេកានិចមិនអាចសម្លាប់វាបានទាំងស្រុងទេ។ ការសម្របខ្លួនរបស់វាខ្ពស់ ដូច្នេះធ្វើឱ្យពិបាកកម្ចាត់តាមរយៈវិធីសាស្ត្រមេកានិចឬតាមរយៈប្រព័ន្ធបញ្ចេញបញ្ចូលទឹក (ស្រូវ)។



# ស្ទីឡូ
# Stylosanthes guianensis









## អត្តសញ្ញាណ

| | |
|---|---|
| ឈ្មោះទូទៅ | ស្ទីឡូ |
| ឈ្មោះវិទ្យាសាស្ត្រ | ***Stylosanthes guianensis*** |
| គ្រួសារ | **Fabaceae** |

## លក្ខណៈរូបសាស្ត្រ

| | |
|---|---|
| កម្ពស់ | រហូតដល់ ១៥០ ស.ម |
| ប្រព័ន្ធឫស | ១៥០-២៥០ ស.ម |
| ទម្ងន់១ ០០០គ្រាប់ | ៥,៧ ក្រាម |
| ទំហំគ្រាប់ពូជ | ១,៥-២ ម.ម |
| ពេលវេលាចេញផ្កា \| អំបូរសណ្ដែករយៈពេល | ១២០ ថ្ងៃ \| ៣ ឆ្នាំ |
| រំលែង | ៦០០ ទៅ > ២ ០០០ ម.ម/ឆ្នាំ |
| របបទឹកភ្លៀង | ប្រកាន់រដូវ (ផ្កាពីខែតុលាទៅខែវិច្ឆិកា) |
| ភាពប្រកាន់រដូវ | ១៥ តោន/ហ.ត (ដីខ្សោះជីជាតិ) |
| ជីវម៉ាស់ស្រស់ | ៤០ តោន/ហ.ត (ដីមានជីជាតិ) |
| ជីវម៉ាស់ស្ងួត | ៣ តោន/ហ.ត (ដីខ្សោះជីជាតិ)<br>៨ តោន/ហ.ត (ដីមានជីជាតិ) |

## ការដាំដុះ

| | |
|---|---|
| ពេលវេលាដាំដុះ | ដាំចន្លោះដំណាំពោត ឬក្នុងខែកញ្ញា |
| ការដាំជាជួរដោយម៉ាស៊ីន | ៦-៨ គ.ក្រ/ហ.ត |
| គម្លាតជួរដាំដោយម៉ាស៊ីន | ២០-៤០ ស.ម |
| ការដាំដោយដៃ | ៨-៩ គ.ក្រ/ហ.ត |
| គម្លាតជួរដាំដោយដៃ | ២០-៤០ ស.ម |
| ការព្រោះ | ៨-១០ គ.ក្រ/ហ.ត |

## ដី & ទឹក

ការទប់ស្កាត់សំណឹកដី
ភាពធន់នឹងគ្រោះរាំងស្ងួត
ការសម្របខ្លួនទៅនឹងដីមានជីជាតិទាប
ការសម្របខ្លួនទៅនឹងដីជាំទឹក
ការសម្របខ្លួនទៅនឹងដីខ្ចៅ (ដីអាល់កាឡាំង)



## សារធាតុចិញ្ចឹម

| | |
|---|---|
| អាសូត (សារធាតុស្ងួត) | ១,៨ ទៅ ៣,៥% |
| ផូស្វ័រ (សារធាតុស្ងួត) | ០,២៥ ទៅ ០,៦% |
| ប៉ូតាស្យូម (សារធាតុស្ងួត) | ០,៨ ទៅ ២,០% |

## ការណែនាំ

អត្ថប្រយោជន៍៖ វាសមស្របទៅនឹងដីច្រើនប្រភេទជាពិសេសដីអាស៊ីតមានជីជាតិទាប។ ដោយសារការផលិតជីវម៉ាស់ដ៏ច្រើនរបស់វា ដំណាំនៅតែរក្សាភាពបៃតងទោះស្ថិតក្នុងរដូវប្រាំង។ ជាដំណាំគម្របដីដ៏ល្អបំផុតសម្រាប់ដាំក្នុងដំណាំជាច្រើន (ស្រូវ ពោត សណ្ដែកសៀង...) ដែលជួយដល់ការអនុវត្តកសិកម្មអភិរក្សប្រើប្រាស់ធាតុចូលតិចតួចបំផុតឬក៏មិនប្រើប្រាស់ធាតុចូលតែម្តង។ ការកម្ចាត់ដោយមេកានិចគឺត្រូវប្រើរ៉ូឡូកាត់។ វាជាជម្រើសដំណាំគម្របដីដ៏ល្អសម្រាប់ដាំក្នុងចម្ការកៅស៊ូ ចេក ស្វាយជាដើម។

ចំណុចយកចិត្តទុកដាក់៖ស្ទីឡូមានការលូតលាស់មិនល្អនៅលើដីអាល់កាឡាំង (ស្រុករតនមណ្ឌល ខេត្តបាត់ដំបង)។



# សណ្តែកកក្តិក
# Vigna umbellata









## អត្តសញ្ញាណ

| | |
|---|---|
| ឈ្មោះទូទៅ | សណ្តែកកត្តិក |
| ឈ្មោះវិទ្យាសាស្ត្រ | ***Vigna umbellata*** |
| គ្រួសារ | **Fabaceae** |

## លក្ខណៈរូបសាស្ត្រ

| | |
|---|---|
| កម្ពស់ | ១០០ ស.ម |
| ប្រព័ន្ធឫស | ១៥០-២៥០ ស.ម |
| ទម្ងន់១ ០០០គ្រាប់ | ១០៣,៨ ក្រាម |
| ទំហំគ្រាប់ពូជ | ១,៥-២ ម.ម |
| ពេលវេលាចេញផ្កា \| អំបូរសណ្តែករយៈពេលខ្លី | ឧសភា - វិច្ឆិកា \| ១៨០ ថ្ងៃ |
| របបទឹកភ្លៀង | ៦០០-១ ៥០០ ម.ម / ឆ្នាំ |
| ភាពប្រកាន់រដូវ | ប្រកាន់រដូវ |
| ជីវម៉ាស់ស្រស់ | ១៥-៣៥ តោន/ហ.ត |
| ជីវម៉ាស់ស្ងួត | ៣-៧ តោន/ហ.ត |

## ការដាំដុះ

| | |
|---|---|
| ពេលវេលាដាំដុះ | ដាំចន្លោះដំណាំពោត ឬក្នុងខែកញ្ញា |
| ការដាំជាជួរដោយម៉ាស៊ីន | ១២-១៤ គ.ក្រ/ហ.ត |
| គម្លាតជួរដាំដោយម៉ាស៊ីន | ៤០-៥០ ស.ម |
| ការដាំដោយដៃ | ១០-១២ គ.ក្រ/ហ.ត |
| គម្លាតជួរដាំដោយដៃ | ៤០-៦០ ស.ម |
| ការព្រោះ | ២០ គ.ក្រ/ហ.ត |

## ដី & ទឹក

ការទប់ស្កាត់សំណឹកដី

ភាពធន់នឹងគ្រោះរាំងស្ងួត

ការសម្របខ្លួនទៅនឹងដីមានជីជាតិទាប

ការសម្របខ្លួនទៅនឹងដីជាំទឹក

ការសម្របខ្លួនទៅនឹងដីខ្លៅ (ដីអាល់កាឡាំង)



## សារធាតុចិញ្ចឹម

| | |
|---|---|
| អាសូត (សារធាតុស្ងួត) | ១,២ ទៅ ២,៥% |
| ផូស្វ័រ (សារធាតុស្ងួត) | ០,២៣ ទៅ ០,៦៥% |
| ប៉ូតាស្យូម (សារធាតុស្ងួត) | ០,៥ ទៅ ១,៥% |

## ការណែនាំ

អត្ថប្រយោជន៍៖ សណ្តែកកត្តិកក៏ជាដំណាំផ្តល់សាច់ប្រាក់សម្រាប់កសិករបង្កើតប្រាក់ចំណូលផងដែរ។ ក្រៅពីផ្តល់សារធាតុចិញ្ចឹមខ្ពស់ វាក៏មានសារៈសំខាន់ណាស់ក្នុងការចាប់យកសារធាតុអាសូត និងមានសមត្ថភាពក្នុងការកែលម្អសុខភាពដីផងដែរ។ សណ្តែកកត្តិកអាចត្រូវបានដាំដុះចន្លោះដំណាំពោត ឬដាំដុះបន្ទាប់ពីដំណាំពោត។ តម្រូវការធាតុចូលតិចតួច។ វានៅតែបន្តរស់រានបាននៅរដូវប្រាំង។ វាត្រូវបានដាំដុះដើម្បីកាត់បន្ថយសម្ពាធស្មៅចង្រៃ។

ចំណុចយកចិត្តទុកដាក់៖ សណ្តែកកត្តិកគឺជារុក្ខជាតិវល្លិអាចនាំឱ្យពន្យាពេលវេលាប្រមូលផលដំណាំពោតនៅពេលដាំដុះរួមគ្នា។ ការប្រមូលផលត្រូវការកម្លាំងពលកម្មច្រើន។



# សណ្តែកអង្គួយ
# *Vigna unguiculata*









## អត្តសញ្ញាណ

| | |
|---|---|
| ឈ្មោះទូទៅ | សណ្ដែកអង្គុយ |
| ឈ្មោះវិទ្យាសាស្ត្រ | ***Vigna unguiculata*** |
| គ្រួសារ | **Fabaceae** |

## លក្ខណៈរូបសាស្ត្រ

| | |
|---|---|
| កម្ពស់ | ៤០ ស.ម |
| ប្រព័ន្ធឫស | ៧០-១៥០ ស.ម |
| ទម្ងន់១ ០០០គ្រាប់ | ១០៣,៨ ក្រាម |
| ទំហំគ្រាប់ពូជ | ១,៥-២ ម.ម |
| ពេលវេលាចេញផ្កា \| អំបូរសណ្ដែករយៈពេលខ្លី | ៦០ ថ្ងៃ \| ១២០ ថ្ងៃ |
| របបទឹកភ្លៀង | ៣០០-២ ០០០ ម.ម/ឆ្នាំ |
| ភាពប្រកាន់រដូវ | ទាំងប្រកាន់និងមិនប្រកាន់រដូវអាស្រ័យលើប្រភេទពូជ |
| ជីរម៉ាស់ស្រស់ | ១០-៣៥ តោន/ហ.ត |
| ជីរម៉ាស់ស្ងួត | ៣-៧ តោន/ហ.ត |

## ការដាំដុះ

| | |
|---|---|
| ពេលវេលាដាំដុះ | ដើមរដូវវស្សា ឬខែកញ្ញា/តុលា |
| ការដាំជាជួរដោយម៉ាស៊ីន | ១៥-២៥ គ.ក្រ/ហ.ត |
| គម្លាតជួរដាំដោយម៉ាស៊ីន | ២២-៦០ ស.ម |
| ការដាំដោយដៃ | ១៥-២៥ គ.ក្រ/ហ.ត |
| គម្លាតជួរដាំដោយដៃ | ៤០-៦០ ស.ម |
| ការព្រោះ | ២៥-៣០ គ.ក្រ/ហ.ត |

## ដី & ទឹក

ការទប់ស្កាត់សំណឹកដី

ភាពធន់នឹងគ្រោះរាំងស្ងួត

ការសម្របខ្លួនទៅនឹងដីមានជីជាតិទាប

ការសម្របខ្លួនទៅនឹងដីជាំទឹក

ការសម្របខ្លួនទៅនឹងដីខ្មៅ (ដីអាល់កាឡាំង)

## សារធាតុចិញ្ចឹម

| | |
|---|---|
| អាសូត (សារធាតុស្ងួត) | ២,០ ទៅ ៤,០% |
| ផូស្វ័រ (សារធាតុស្ងួត) | ០,១ ទៅ ០,៣% |
| ប៉ូតាស្យូម (សារធាតុស្ងួត) | ១,០ ទៅ ២,៥% |

## ការណែនាំ

អត្ថប្រយោជន៍៖ សណ្ដែកអង្គុយក៏ជាដំណាំផ្ដល់សាច់ប្រាក់ផងដែរ។ វាជាដំណាំគម្របដីដ៏ល្អប្រសើរដោយផ្ដល់ផលប្រយោជន៍ជាច្រើនសម្រាប់សុខភាពដី។ ប្រព័ន្ធឫសដ៏ជ្រៅរបស់សណ្ដែកអង្គុយជួយឱ្យដីមានខ្យល់ចេញចូលបានល្អ កែលម្អរចនាសម្ព័ន្ធដីដោយបង្កើនជម្រាបទឹកក្នុងដី និងកាត់បន្ថយភាពហាប់នៃដី។ ពូជ SPLM2 គឺធន់នឹងគ្រោះរាំងស្ងួត ហើយនៅតែរក្សាពណ៌បៃតងក្នុងរដូវប្រាំងដែលមានក្នុងតំបន់មួយចំនួនក្នុងខេត្តកំពង់ចាម។

ចំណុចយកចិត្តទុកដាក់៖ ត្រូវជ្រើសរើសពូជដែលត្រូវនឹងគោលបំណងរបស់អ្នក (ដុះលូតលាស់លឿន អាយុកាលខ្លីឬវែង ដើមត្រង់ឬវល្លិ សម្រាប់ផលិតគ្រាប់ពូជឬជាចំណីសត្វ....)។



គ្រួសារ

# Malvaceae

©CARDEC, Kampong Cham



# ក្រចៅ
# Corchorus capsularis









## អត្តសញ្ញាណ

| | |
|---|---|
| ឈ្មោះទូទៅ | ក្រចៅ |
| ឈ្មោះវិទ្យាសាស្ត្រ | ***Corchorus capsularis*** |
| គ្រួសារ | **Malvaceae** |

## លក្ខណៈរូបសាស្ត្រ

| | |
|---|---|
| កម្ពស់ | ៥០០ ស.ម |
| ប្រព័ន្ធឫស | ១៥០-២៥០ ស.ម |
| ទម្ងន់១ ០០០គ្រាប់ | ២៥-២៧ ក្រាម |
| ទំហំគ្រាប់ពូជ | ១,៥-២ ម.ម |
| ពេលវេលាចេញផ្កា \| អំបូរ mallows រយៈពេលខ្លី | ១១៥ ថ្ងៃ \| ១៥០ ថ្ងៃ |
| របបទឹកភ្លៀង | ១ ០០០-២ ០០០ ម.ម/ឆ្នាំ |
| ភាពប្រកាន់រដូវ | ប្រកាន់រដូវ |
| ជីវម៉ាស់ស្រស់ | ១៥-៣៥ តោន/ហ.ត |
| ជីវម៉ាស់ស្ងួត | ៣-៧ តោន/ហ.ត |

## ការដាំដុះ

| | |
|---|---|
| ពេលវេលាដាំដុះ | ខែមេសា- ដើមខែឧសភា ឬ ខែកញ្ញា/តុលា |
| ការដាំជាជួរដោយម៉ាស៊ីន | ៨ - ៩ គ.ក្រ/ហ.ត |
| គម្លាតជួរដាំដោយម៉ាស៊ីន | ១៧-៣៤ ស.ម |
| ការដាំដោយដៃ | ៩-១០ គ.ក្រ/ហ.ត |
| គម្លាតជួរដាំដោយដៃ | ២៥-៥០ ស.ម |
| ការព្រោះ | ១២-១៤ គ.ក្រ/ហ.ត |

## ដី & ទឹក

- ការទប់ស្កាត់សំណឹកដី
- ភាពធន់នឹងគ្រោះរាំងស្ងួត
- ការសម្របខ្លួនទៅនឹងដីមានជីជាតិទាប
- ការសម្របខ្លួនទៅនឹងដីជាំទឹក
- ការសម្របខ្លួនទៅនឹងដីខ្មៅ (ដីអាល់កាឡាំង)

## សារធាតុចិញ្ចឹម

| | |
|---|---|
| អាសូត (សារធាតុស្ងួត) | ១,៥ ទៅ ២,៥% |
| ផូស្វ័រ (សារធាតុស្ងួត) | ០,០៥ ទៅ ០,២% |
| ប៉ូតាស្យូម (សារធាតុស្ងួត) | ១,០ ទៅ ៣,០% |

## ការណែនាំ

**អត្ថប្រយោជន៍៖** ដោយសារតែសមត្ថភាពក្នុងការផលិតជីវម៉ាសបានយ៉ាងឆាប់រហ័ស ក្រចៅត្រូវបានគេដាំជាដំណាំគម្របដីមុន(ឬក្រោយ)ដំណាំចម្បង ដើម្បីផលិតសារធាតុចិញ្ចឹមឡើងវិញ។ វាមានអត្ថប្រយោជន៍យ៉ាងសំខាន់ក្នុងការទប់ស្កាត់សំណឹកដី ការទប់ស្កាត់ស្មៅចង្រៃ និងការកែលម្អរចនាសម្ព័ន្ធនិងគុណភាពដីតាមរយៈប្រព័ន្ធឫសរបស់វា។ វាជាដំណាំដែលធន់នឹងគ្រោះរាំងស្ងួត។

**ចំណុចយកចិត្តទុកដាក់៖** ដើមក្រចៅមានជាតិសរសៃនិងស្វិតខ្លាំងដែលធ្វើឱ្យមានការពុកផុយយឺត និងស្រូបទុកសារធាតុអាសូតនៅក្នុងដីបានរយៈពេលខ្លី។



# ក្រចៅបន្លា
## *Hibiscus cannabinus*









## អត្តសញ្ញាណ

| | |
|---|---|
| ឈ្មោះទូទៅ | ក្រចៅបន្លា |
| ឈ្មោះវិទ្យាសាស្ត្រ | ***Hibiscus cannabinus*** |
| គ្រួសារ | **Malvaceae** |

## លក្ខណៈរូបសាស្ត្រ

| | |
|---|---|
| កម្ពស់ | ៣០០ ស.ម |
| ប្រព័ន្ធឫស | ១៥០-២៥០ ស.ម |
| ទម្ងន់១ ០០០គ្រាប់ | ៣០ ក្រាម |
| ទំហំគ្រាប់ពូជ | ៣ ម.ម |
| ពេលវេលាចេញផ្កា \| អំបូរ mallows រយៈពេលខ្លី | ១១៥ ថ្ងៃ \| ១៥០ ឆ្នាំ |
| របបទឹកភ្លៀង | ៦០០-១ ៦០០ ម.ម/ឆ្នាំ |
| ភាពប្រកាន់រដូវ | ប្រកាន់រដូវ |
| ជីវម៉ាស់ស្រស់ | ៧៥ តោន/ហ.ត |
| ជីវម៉ាស់ស្ងួត | ១៥ តោន/ហ.ត |

## ការដាំដុះ

| | |
|---|---|
| ពេលវេលាដាំដុះ | ខែមេសា - ខែឧសភា |
| ការដាំជាជួរដោយម៉ាស៊ីន | ៨-៩ គ.ក្រ/ហ.ត |
| គម្លាតជួរដាំដោយម៉ាស៊ីន | ២២-៤៤ ស.ម |
| ការដាំដោយដៃ | ៨-៩ គ.ក្រ/ហ.ត |
| គម្លាតជួរដាំដោយដៃ | ២៥-៤៥ ស.ម |
| ការព្រោះ | ១០-១២ គ.ក្រ/ហ.ត |

## ដី & ទឹក

ការទប់ស្កាត់សំណឹកដី

ភាពធន់នឹងគ្រោះរាំងស្ងួត

ការសម្របខ្លួនទៅនឹងដីមានជីជាតិទាប

ការសម្របខ្លួនទៅនឹងដីជាំទឹក

ការសម្របខ្លួនទៅនឹងដីខ្មៅ (ដីអាល់កាឡាំង)



## សារធាតុចិញ្ចឹម

| | |
|---|---|
| អាសូត (សារធាតុស្ងួត) | ០,៥ ទៅ ២,៥% |
| ផូស្វ័រ (សារធាតុស្ងួត) | ០,២ ទៅ ១,០% |
| ប៉ូតាស្យូម (សារធាតុស្ងួត) | ១,០ ទៅ ៣,០% |

## ការណែនាំ

**អត្ថប្រយោជន៍៖** វាមានសមត្ថភាពខ្ពស់ក្នុងការផលិតជីវម៉ាសបានបរិមាណដ៏ច្រើនក្នុងពេលយ៉ាងឆាប់រហ័ស។ ដាំជាដំណាំគម្របដីមុន(ឬក្រោយ)ដំណាំចម្បងដើម្បីផលិតសារធាតុចិញ្ចឹមឡើងវិញ។ ក្រចៅបន្លាមានគុណសម្បត្តិដ៏អស្ចារ្យដូចជាការបញ្ឈប់ការហូរច្រោះ ការកែលម្អរចនាសម្ព័ន្ធនិងគុណភាពដីតាមរយៈប្រព័ន្ធឫសដ៏រឹងមាំនិងក្រាស់របស់វា។ វាជាប្រភេទដំណាំដែលធន់នឹងគ្រោះរាំងស្ងួត។ ការផលិតគ្រាប់ពូជបានច្រើន និងសម្របខ្លួនបានយ៉ាងល្អលើប្រភេទដីមួយចំនួនធំនឹងលក្ខខណ្ឌជាច្រើនប្រភេទ (លក្ខខណ្ឌអាស្រ័យទឹកភ្លៀង នឹងដីជាំទឹក រួមទាំងលក្ខខណ្ឌមានប្រព័ន្ធស្រោចស្រព)។

**ចំណុចយកចិត្តទុកដាក់៖** វាមានការសម្របខ្លួនខ្ពស់និងផលិតគ្រាប់ពូជបានច្រើនលើដីគ្រប់ប្រភេទ ត្រូវធ្វើការកម្ចាត់ក្រចៅបន្លាមុនពេលដំណាក់កាលគ្រាប់ទុំប្រសិនបើដាំជាដំណាំគម្របដី។

# សេចក្តីថ្លែងអំណរគុណ

សៀវភៅណែនាំនេះ គឺជាសមិទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់បុគ្គលដែលមានចំណង់ចំណូលចិត្តក្នុងការជម្រុញវិស័យកសិកម្មប្រកបដោយចីរភាពតាមរយៈការដាំដំណាំគម្របដី។ ជំនាញការងារ ការយល់ដឹង និងការប្តេជ្ញាចិត្តរបស់ពួកគេពិតជាមានតម្លៃមិនអាចកាត់ថ្លៃបានក្នុងការចងក្រងខ្លឹមសារនៃសៀវភៅនេះ និងធានាថាវាពិតជាមានការពាក់ព័ន្ធសម្រាប់ប្រព័ន្ធកសិកម្មចម្រុះ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះក្រុមការងារនៅស្ថានីយស្រាវជ្រាវកសិកម្មអភិរក្សបុស្សខ្នុរ បាត់ដំបង និងព្រះវិហារ ក៏ដូចជាដៃគូសហការផ្សេងៗចំពោះការចូលរួមចំណែកដ៏មានតម្លៃរបស់ពួកគេ។ សូមកោតសរសើរជាពិសេសចំពោះ: សេន រស្មី, ខ្លូត ធារ៉ា, គន់ សុផល, ស្រី រ៉ាម៉ា, ស៊ឹម សំណាង, ជួន ឡៀន, ផល សុផាត, តៃ បណ្ឌិត, ធី វ៉ាន់ដេត, ម៉ាក ភារម្យ, ស៊ាម ណូ, ហេង លាភា, ផេង ភូមរិន្ទ, មឿន សុណារ័ត្ន, នួន ឋានន្តរ៍, ស្រេង មករា, សឿម សុឌីណា, ហោ គីមហ៊ត់, សៀង រក្សា, ធួក វ៉ាលីសៀវម៉ី, Ricky Bates, David Ader, Mannuel Reyes, Camille Giraudet, និង អឿ វារីជា។

សៀវភៅណែនាំនេះត្រូវបានចងក្រងឡើង ដោយសារការប្តេជ្ញាចិត្តខ្ពស់របស់លោកអ្នកក្នុងការអនុវត្តកសិអេកូឡូស៊ី និងការ ចែករំលែកចំណេះដឹងដ៏មានតម្លៃនេះ។








Layout by Vearyda Oeu,
ASSET Project, 2025




សៀវភៅនេះត្រូវបានចងក្រងឡើងដោយផ្អែកលើចំណេះដឹង និងបទពិសោធន៍ដែលទទួលបានពីគម្រោងវិវឌ្ឍនាការកសិអេកូឡូស៊ីនិងស្បៀងអាហារសុវត្ថិភាព (ASSET) និងកម្មវិធីការគ្រប់គ្រងទឹកនិងវិវឌ្ឍនាការកសិកម្មអេកូឡូស៊ីនៅកម្ពុជា (WAT4CAM) ក្នុងឆ្នាំ ២០២៥។